**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ការិយាល័យអ្នកនាំពាក្យ**

**លេខ ៣២២ សប្រក**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី

## ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៥

ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៥ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លង :

**១-សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា**

**២-សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម**

**៣-បញ្ហាផ្សេងៗ**

ក្រោយពីបានពិភាក្សានិងផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសំរេចឯកភាព :

### I-លើសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា

សេចក្តីព្រាងរាជក្រឹត្យនេះ ត្រូវបានក្រសួងសុខាភិបាលរៀបចំឡើងក្នុងគោលបំណងប្រមូលផ្តុំទន្តពេទ្យទាំងអស់ដែលមានកាយសម្បទាគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈទន្តសាស្ត្រនៅកម្ពុជា អោយមានការប្រព្រឹត្តទៅដោយគោរពតាមបណ្តាគោលការណ៍សីលធម៌ ភាពសុចរិត យុត្តិធម៌ និងមានភក្តីភាព ក្នុងការប្រកបវិជ្ជាទន្តសាស្ត្រ ទើបធានាបាននូវ ប្រសិទ្ធភាពខ្ពស់ និងការពារកិត្តិយស វិជ្ជាជីវៈទន្តសាស្ត្រ ក៏ដូចជាការពារកិត្តិយសកម្ពុជាលើឆាកអន្តរជាតិផងដែរ ។ ទន្ទឹមនឹងនេះកម្ពុជាយើងគឺជាសមាជិកអាស៊ាន សមាជិកបណ្តាអនុតំបន់ទន្លេមេគង្គ សមាជិកសហព័ន្ធទន្តពេទ្យពិភពលោក សមាជិកបណ្ឌិតសភាទន្តសាស្ត្រពិភពលោក ដូច្នេះតំរូវអោយមានគណៈទន្តពេទ្យមួយតំណាងព្រះរាជាណាចក្រកម្ពុជាសំរាប់ចូលរួមជាមួយគណៈទន្តពេទ្យបណ្តាប្រទេសសមាជិកអង្គការអន្តរជាតិទាំងនោះ ។

### II-លើសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានរៀបចំចងក្រងសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម **(SME – Small and Medium Enterprise)** ដោយទទួលបានការគាំទ្រផ្នែកបច្ចេកទេសពី សំណាក់ធនាគារ អភិវឌ្ឍន៍អាស៊ី **(ADB)** ក្នុងគោលបំណងយកធ្វើជាផែនទីចង្អុលបង្ហាញសំរាប់ការ អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម និង សំដៅបង្កើនប្រសិទ្ធភាព

បរិយាកាសអាជីវកម្មដោយភាពអនុគ្រោះដែលអាចនាំ SME ទៅរកលក្ខណៈប្រកួតប្រជែង ដើម្បីរួមចំណែកនៅក្នុងការបង្កើតការងារប្រកបដោយគុណភាព និងធ្វើអោយប្រសើរឡើងនូវបរិមាណ និងគុណភាព ទំនិញ និងសេវាសំរាប់ប្រជាជនកម្ពុជា ។

ម្យ៉ាងវិញទៀតសេចក្តីព្រាងក្របខ័ណ្ឌ SME នេះ គឺឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលបានចេញនូវគោលនយោបាយ ១៣ ចំណុច សំរាប់ SME គឺ ១-លើកទឹកចិត្តការអភិវឌ្ឍន៍ SME ជាពិសេសតាមរយៈការផ្តល់ឥណទានរយៈពេលមធ្យម និងរយៈ ពេលវែង, ២-បង្រ្កាបការរត់ពន្ធ, ៣-កាត់បន្ថយបែបបទ សំរាប់ការចុះបញ្ជីនិងការរៀបចំដំណើរការក្រុមហ៊ុន, ៤-សំរួលដល់សកម្មនាំចេញ-នាំចូល ដោយសំរួលបែបបទនានាដូចជា ការចេញអាជ្ញាប័ណ្ណនិងលិខិតអនុញ្ញាតិផ្សេងៗ, ៥-គាំទ្រដល់ឧស្សាហកម្មទំនើបបង្កើតថ្មីក្នុងរយៈពេលសមស្របមួយ, ៦-លើក កំពស់ទំនាក់ទំនងរវាង SME និងសហគ្រាសធុនធំៗ, ៧-ជួយ SME ក្នុងការបង្កើតផលិតភាពរបស់ខ្លួន និងការបន្ថយថ្លៃដើមផលិតកម្ម, ៨-នានាគុណភាពផលិតផលក្នុងស្រុកដើម្បីឆ្លើយតបទៅនឹងបទដ្ឋានក្នុងតំបន់ និងអន្តរជាតិ, ៩-បង្កើតមន្ទីរ ពិសោធន៍ជាតិដើម្បីធ្វើតេស្តពិនិត្យគុណភាព និងលក្ខណៈវិនិច្ឆ័យនៃផលិតផល, ១០-ពង្រឹងយន្តការសំរាប់ការពារកម្មសិទ្ធិបញ្ញា ផ្នែកឧស្សាហកម្ម, ១១-ជំរុញការបណ្តុះបណ្តាលវិជ្ជាជីវៈ ជំនាញ ទាំងក្នុងស្រុក និងក្រៅស្រុក, ១២-ពង្រីក និងបង្កើនកម្មវិធី "ភូមិ ១ ផលិតផល ១" និងទី ១៣-គឺពង្រឹងក្របខ័ណ្ឌច្បាប់ដោយបង្កើតច្បាប់ និងបទដ្ឋានផ្សេងៗ ។

**III-អំពីបញ្ហាផ្សេងៗ**

តាមសេចក្តីរាយការណ៍របស់ក្រសួងធនធានទឹក និងឧត្តុនិយម និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយស្តីពីស្ថានភាពកើនឡើងនៃកំពស់ទឹកទន្លេនៅស្ថានីយ៍ខេត្តក្រចេះ (ពី ១៨,១០ ម៉ែត្រ នៅថ្ងៃទី ២៨ កក្កដា ២០០៥ ឡើងដល់ ១៩,២០ ម៉ែត្រ នៅព្រឹកថ្ងៃទី ២៩ កក្កដា ២០០៥) សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ណែនាំអោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអាជ្ញាធរដែនដីនៅតាមដងទន្លេក្នុងព្រះរាជាណាចក្រកម្ពុជា អោយធ្វើការត្រៀមលក្ខណៈបង្ការ និងទប់ស្កាត់គ្រោះមហន្តរាយពីទឹកជំនន់ដែលអាចកើតឡើងជាយថាហេតុ ។

ម្យ៉ាងវិញទៀតជាវិធានការចំពោះមុខដើម្បីទប់ស្កាត់ និងលើកស្ទួយតំលៃប្រាក់រៀលដែលកំពុងធ្លាក់ចុះដោយកត្តាសត្យានុម័តផ្សេងៗ ក៏ដូចជាការបង្កើននូវជំនឿទុកចិត្តរបស់សាធារណៈជនមកលើប្រាក់រៀល សម្តេចនាយករដ្ឋមន្ត្រីបានផ្តល់អនុសាសន៍ និងបទបញ្ជាដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិកម្ពុជា និងក្រសួងផ្សេងៗដែលមានការពាក់ព័ន្ធទៅនឹងការធ្វើចរាចរសាច់ប្រាក់នៅលើទីផ្សារ ព្រមទាំងអាជ្ញាធរខេត្ត-ក្រុងនានា ត្រូវជំរុញអោយមានការប្រើប្រាស់ និងគ្រប់គ្រងសាច់ប្រាក់រៀលជំនួសការប្រើប្រាស់រូបិយ ប័ណ្ណបរទេសទាំងក្នុងទីផ្សារឯកជន និងក្នុងការប្រមូលចំណូលផ្សេងៗចូលរដ្ឋ ។

អង្គប្រជុំគណៈរដ្ឋមន្ត្រីបានបិទសម័យប្រជុំនៅម៉ោង ១២ និង ១៥ នាទី ។

ភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ២០០៥